# ពិធីចុះហត្ថលេខារវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយក្រុមហ៊ុន **Kim Mex Construction & Investment Co,Ltd** ស្តីពីគម្រោងផ្គត់ផ្គង់ទឹកស្អាត ខេត្តមណ្ឌលគិរី ក្នុងក្របខណ្ឌគម្រោងអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា ឡាវ វៀតណាម ក្រោមហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន



បន្ទាប់ពីចេញប្រកាសសម្រេចចាត់តាំងគណៈកម្មការលទ្ធកម្មអន្តរក្រសួង ដើម្បីពិនិត្យនិងវាយតម្លៃលទ្ធកម្ម គម្រោងផ្គត់ផ្គង់ទឹកស្អាត ខេត្តមណ្ឌលគិរី ក្នុងក្របខណ្ឌគម្រោងអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា ឡាវ វៀតណាម ក្រោមហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន ដែលចុះហត្ថលេខា ដោយឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រួចមក ក្រុមហ៊ុន Kim Mex Construction & Investment Co,Ltd ត្រូវបានគណៈកម្មការលទ្ធកម្មអន្តរក្រសួង ធ្វើការវាយតម្លៃ និងជ្រើសរើសជាក្រុមហ៊ុនទទួលសិទ្ធិអភិវឌ្ឍន៍គម្រោងផ្គត់ផ្គង់ទឹកស្អាតនៅខេត្តមណ្ឌលគិរី ក្នុងក្របខណ្ឌគម្រោងអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា ឡាវ វៀតណាម ក្រោមហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន ហើយត្រូវបានរៀបចំពិធីចុះហត្ថលេខា នៅព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ នៅទីស្តីការក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ហត្ថលេខី នៃពិធីនេះ គឺរវាងឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយលោក **ទូច គីម** នាយកក្រុមហ៊ុន **Kim Mex**

**Construction & Investment Co,Ltd** ដោយមានការចូលរួមជាសាក្សីពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញក្រោមឱវាទក្រសួង និងតំណាងមកពីក្រុមហ៊ុនមួយចំនួនទៀត ។





ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានបង្ហាញនូវទឹកចិត្តរីករាយ ចំពោះពិធីចុះហត្ថលេខានាថ្ងៃនេះ និងផ្តល់នូវជំនឿថា៖តាមរយៈបទពិសោធន៍របស់ក្រុមហ៊ុន ក្រុមហ៊ុននឹងអនុវត្តបានជោគជ័យនូវគម្រោងផ្គត់ផ្គង់ទឹកស្អាត ក្នុងក្របខណ្ឌគម្រោងអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា ឡាវ វៀតណាម ក្រោមហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន ដើម្បីឱ្យប្រជាពលរដ្ឋនៅខេត្តមណ្ឌលគីរី ក្នុងទីក្រុង សែនមនោរម្យ ទទួលបានទឹកស្អាតប្រើប្រាស់ ក្នុងការលើកកំពស់សុខភាពអនាម័យ និងការកាត់បន្ថយភាពក្រីក្រ សម្រាប់ប្រជាពលរដ្ឋក្នុងតំបន់ភូមិភាគឦសានមួយនេះ ។



លោក **ទូច គីម** នាយកក្រុមហ៊ុន Kim Mex Construction & Investment Co,Ltd បាន ថ្លែងអំណរគុណចំពោះគណៈកម្មការលទ្ធកម្មអន្តរក្រសួង ដែលបានវាយតម្លៃយ៉ាងសុក្រឹត និងបានជ្រើសរើសក្រុមហ៊ុនរបស់លោក ក្នុងការផ្គត់ផ្គង់ទឹកស្អាត នៅខេត្តមណ្ឌលគីរី ក្នុងក្របខណ្ឌគម្រោងអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា ឡាវ វៀតណាម ក្រោមហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន។



លោកនាយកក្រុមហ៊ុន បានបង្ហាញនូវការប្តេជ្ញាចិត្ត ដើម្បីសម្រេចឱ្យបាននូវគម្រោងផ្គត់ផ្គង់ទឹកស្អាត ក្នុងទីក្រុងសែនមនោរម្យ ក្នុងខេត្តមណ្ឌលគិរី យ៉ាងយូរឱ្យបានមុនចូលឆ្នាំប្រពៃណីខ្មែរ នាឆ្នាំ២០១៦ ខាងមុខ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមកិច្ចព្រមព្រៀង ដែលបានចុះហត្ថលេខា ធ្វើយ៉ាងណាឱ្យការតបណ្តាញ និងគុណភាពទឹកទទួលបានសុវត្ថិភាព និងស្តង់ដា សម្រាប់អ្នកប្រើប្រាស់ទូទៅ ។